# ទំនុកដំកើង ១២២

អ្នកនិពន្ធ រុហ្វ លេភិឡារ

ស្តេចដាវីឌហាក់ដូចជាបានសរសេរទំនុកដំកើងនេះសំរាប់ឲ្យប្រជាជនអ៊ីស្រាអែលបានប្រើប្រាស់នៅពេលពួកគេបានមកឯយេរូសាឡឹមដើម្បីថ្វាយបង្គំនៅក្នុងពិធីបុណ្យទាំងបី (ចោទិយកថា ១៦:១-១៧)។ គឺវានៅក្នុងសម័យរបស់ស្តេចដាវីឌដែលយេរូសាឡឹមត្រូវបានជ្រើសជាដំបូងជាទីក្រុងដែលព្រះនឹងដាក់ឈ្មោះរបស់ទ្រង់។

អារម្មណ៏របស់អ្នកនិពន្ធទំនុកដំកើងនេះផ្ទុយយ៉ាងខ្លាំងនឹងទំនុកដំកើង១២០។ នៅក្នុងទំនុកដំកើងនេះ អ្នកធម្មយាត្រាមានអំណរដោយព្រោះគាត់បានមកដល់យេរូសាឡឹម។ ការនៅក្នុងយេរូសាឡឹមផ្ទុយពី «ប្រទេសឆ្ងាយ» (១២០:៥) *ពួកបងប្អូន* (១២២:៨) ផ្ទុយពីពួកខ្មាំងសត្រូវដែលមានក្នុង១២០:២, ៧។ ម្តងទៀត មានចលនាឆ្ពោះទៅកាន់យេរូសាឡឹម គឺទំនុកដំកើងនេះចាប់ផ្តើមដោយការប្រកាសការទៅយេរូសាឡឹមហើយភ្លាមៗនាំដល់ការនៅក្នុងយេរូសាឡឹមចាប់ពីខ.២ទៅ។ បទពិសោធន៏ដ៏អស្ចារ្យនៃការនៅក្នុងយេរូសាឡឹម (ខ. ២-៥) នាំទៅដល់សេចក្តីអធិស្ឋានមួយសំរាប់យេរូសាឡឹមនិងមនុស្សដែលរស់នៅក្នុងទីនោះ (ខ. ៦-៩)។ អេសាយ ២៦:១-៤ បង្រៀនថា នៅក្នុងឧបសគ្គជីវិត យើងរស់នៅក្នុង «ទីក្រុងខ្លាំង» (ហេព្រើ ១២.២២) ដោយសេចក្តីជំនឿរួចទៅហើយ។ ដោយសារតែអេសាយ ២៦ *ប្រកាស*អំពីភាពប្រាកដប្រជានៃសន្តិភាពសំរាប់យេរូសាឡឹមដោយកំលាំងរបស់ព្រះ នោះបទគម្ពីរនេះគឺជា*សេចក្តីអធិស្ឋាន*មួយសំរាប់សន្តិភាពនោះឯង។

**ខ. ៣-៤** ទីក្រុងបានបញ្ជាក់អំពីការរួបរួមរបស់ប្រជារាស្ត្ររបស់ព្រះ។ ទ្រង់ទ្រាយរបស់ទីក្រុងប្រាប់យើងថាវា*ណែនណាន់ជាប់គ្នា*។ អស់អ្នកដែលចូលក្នុងទីក្រុងមកពី*ពូជអំបូរ*ខុសៗគ្នា ប៉ុន្តែពួកទាំងអស់*ជារបស់ព្រះអម្ចាស់* ដែលមកដោយការស្តាប់បង្គាប់តាម*ច្បាប់*របស់ព្រះ (ខ. ៤) (សូមមើលចោទិយកថា ១២ និង ១៦:១-១៧ សំរាប់គំរូនៃច្បាប់ទាំងនេះដែលព្រះបានប្រកាសពីមុន)។ ដូច្នេះសេចក្តីពិតមួយដែលបានបង្រួបបង្រួមបូជអំបូរទាំងនេះគឺថា ពួកគេទាំងអស់គ្នាជារបស់ព្រះអម្ចាស់ ពួកគេគឺជាអ្នកស្នងសេចក្តីសន្យានិងសេចក្តីបង្គាប់របស់ព្រះ។ ពួកគេបានធ្វើធម្មយាត្រាទៅកាន់យេរូសាឡឹមដើម្បីថ្វាយការអរព្រះគុណនិងការសរសើរតម្កើង មិនមែនដើម្បីធ្វើពិធីសាសនាក្នុងគោលបំណងទទួលអ្វីដែលអ្នកចង់បានពីព្រះ ដូចជាអ្វីដែលកើតឡើងជារឿយៗនៅក្នុងសាសនាក្លែងក្លាយនោះទេ។

បន្ទាប់ពីស្តេចដាវីឌស្តេចយេរ៉ូបោមបានដឹកនាំអាណាចក្រខាងជើងនៅពេលដែលអ៊ីស្រាអែលត្រូវបានបែងចែកជាពីរ ហើយបានភ័យខ្លាចថាមនុស្សគ្រប់គ្នានឹងត្រឡប់ទៅយេរូសាឡឹមដែលនៅក្នុងយូដាវិញ (១ពង្សាវតារក្សត្រ ១២.២៦...)។ ដូច្នេះយេរ៉ូបោមបានបង្កើតកន្លែងថ្វាយបង្គំផ្សេងៗដែលបាននាំឲ្យប្រជាជនមិនស្តាប់បង្គាប់អ្វីដែលត្រូវបាន*បង្គាប់ឲ្យអ៊ីស្រាអែល*ថ្វាយបង្គំនៅឯយេរូសាឡឹម។

**ខ. ៥** *បល្ល័ង្កតាំងឡើងសំរាប់ការវិនិច្ឆ័យ* ។ នៅក្នុងយេរូសាឡឹមត្រូវមានសេចក្តីសុច្ចរឹតនិងយុត្តិធម៌ក្រោមការដឹកនាំរបស់ស្តេចដែលព្រះជាម្ចាស់បានតែងតាំងតាមវង្សស្តេចដាវីឌ។ ស្តេចគឺជាអំណាចនៃការវិនិច្ឆ័យល្អខ្ពស់បំផុតនៅក្នុងប្រទេស (ក្នុងចំណោមមនុស្ស) ដូច្នេះស្តេចត្រូវស្តាប់រឿងក្តីផ្សេងៗដោយទៀងទាត់។ បល្ល័ង្កត្រូវបានតាំងឡើងសំរាប់គោលបំណងនេះ ទាំងនៅក្នុងសាលសវនាការនៅក្នុងអគារព្រះរាជវាំង ឬនៅឯច្រកទ្វារធំរបស់ទីក្រុង។

**ខ. ៦-៩** ព្យាង្គចុងក្រោយរបស់ឈ្មោះ «យេរូសាឡឹម» ដូចពាក្យហេព្រើដែលបកប្រែ «សន្តិភាព» (*šālôm*) ហើយសន្តិភាពរបស់យេរូសាឡឹមគឺជាផ្ទៃរឿងនៃខគម្ពីរទាំងនេះ។ ខ.៦ក ហៅ ឲ្យមានសេចក្តីអធិស្ឋានមួយសំរាប់យេរូសាឡឹម ហើយខ. ៦ខ-៧ គឺជាសេចក្តីអធិស្ឋានមួយ។ វាលើសជាងសេចក្តីអធិស្ឋានមួយប្រឆាំងនឹងពួកខ្មាំងសត្រូវខាងក្រៅទៅទៀត ទោះបើការលើកឡើងអំពី*កំផែង*បញ្ជាក់ច្បាស់ថាសេចក្តីសុខប្រឆាំងនឹងពួកខ្មាំងសត្រូវខាងក្រៅគឺសំខាន់ (ប្រៀបធៀបៈ ទំនុកដំកើង ៤៨.១២...)។ ទោះយ៉ាងណាសេចក្តីអធិស្ឋាននេះទូលសូមសន្តិភាព «ពីខាងក្នុង»។

នៅក្នុងប្រវត្តិសាស្ត្រ យេរូសាឡឹមបានបរាជ័យក្នុងការធ្វើជាទីក្រុងនៃសន្តិភាពនិងការរួបរួម ហើយព្រះយេស៊ូវបានពិពណ៌នាយេរូសាឡឹមថាជាទីក្រុងមួយដែលបានសំលាប់ពួកហោរា (លូកា ១៣.៣៤)។ ជាចុងក្រោយ លក្ខណៈរបស់យេរូសាឡឹមនេះត្រូវបាន

ឃើញនៅពេលពួកគេបានធ្វើគុតព្រះយេស៊ូវ។ ពួកគេបានគិតថា តាមរយៈការធ្វើគុតព្រះយេស៊ូវ ពួកគេអាចទទួលបាននូវសន្តិភាពសំរាប់យេរូសាឡឹម (យ៉ូហាន ១១.៤៨) តែទោះយ៉ាងណា ទង្វើរបស់ពួកគេបានទទួលលទ្ធផលផ្ទុយទាំងស្រុងដែលជាការវិនាសដែលបានកើតឡើងជាចុងក្រោយនៅក្នុងឆ្នាំ៧០គ.សនៅពេលពួករ៉ូមម៉ាំងបានបំផ្លាញទីក្រុងយេរូសាឡិម។ ព្រះយេស៊ូវបានទាយថា ការនេះនឹងកើតឡើងដោយព្រោះតែពួកគេបរាជ័យក្នុងការទទួលទ្រង់ ហើយដូច្នេះពួកគេមិនបានទទួលស្គាល់អ្វីដែលនឹងនាំមកនូវសន្តិភាពនោះទេ (លូកា ១៩.៤១-៤៤)។

**ការអនុវត្ត**

ដូចដែលទំនុកដំកើង ១២០-១២២ បង្ហាញអំពីអ្នកធម្មយាត្រាដែលតស៊ូក្នុងទុក្ខលំបាកផ្សេងៗប៉ុន្តែស៊ូទ្រាំដោយការចងចាំអំពីគោលដៅយេរូសាឡឹមហើយនិងការមានអំណរនិងសន្តិភាពនៅពេលគាត់មកដល់ គ្រីស្ទបរិស័ទក៏នឹងជួបប្រទះទុក្ខលំបាកផងដែរ ប៉ុន្តែយើងគួរចងចាំគោលដៅយេរូសាឡឹមនៅស្ថានសួគ៌របស់យើង គឺចងចាំថាយើងនឹងមានអំណរនិងសន្តិភាពដ៏ធំនៅទីនោះ។ យើងអាចសំលឹងឆ្ពោះទៅកាន់ការទាំងនោះដោយទំនុកចិត្តយ៉ាងខ្លាំង ពីព្រោះពាក្យនៅក្នុងសំបុត្រយូដាស (ខ. ២៤) ថ្លែងថា ព្រះ «អាចនឹងថែរក្សាមិនឲ្យអ្នករាល់គ្នាជំពប់ដួល» (ប្រៀបធៀបៈ ទំនុកដំកើង ១២១) «ហើយនឹងដាក់អ្នករាល់គ្នានៅចំពោះសិរីល្អទ្រង់ ដោយឥតមានកន្លែងបន្ទោសបាន ព្រមទាំងមានចិត្តត្រេកអរផង» (ប្រៀបធៀបៈ ទំនុកដំកើង ១២២)។

ដូចដែលពួកអ៊ីស្រាអែលត្រូវតែជួបជុំគ្នាជាគ្រួសាររបស់ព្រះដើម្បីសរសេរតម្កើងព្រះនាមរបស់ព្រះយ៉ាវេ ពួកគ្រីស្ទបរិស័ទក៏គួរតែជួបជុំគ្នាជាគ្រួសាររបស់ព្រះនៅក្នុងសម័យសម្ព័ន្ធមេត្រីថ្មីដើម្បីសរសើរតម្កើងព្រះនាមរបស់ព្រះយេស៊ូវដោយអំណរផងដែរ។ វាជាការត្រឹមត្រូវក្នុងការអធិស្ឋានសំរាប់សន្តិភាព ហើយជាពិសេសសន្តិភាពនិងសុវត្ថិភាពសំរាប់ប្រជារាស្ត្ររបស់ព្រះ។ ទោះយ៉ាងណា ប្រវត្តិសាស្ត្ររបស់យេរូសាឡឹមដែលត្រូវបានសង្ខេបខាងលើបង្ហាញថា ទោះបើព្រះគម្ពីរសញ្ញាចាស់លើកទឹកចិត្តឲ្យមានសេចក្តីអធិស្ឋានសំរាប់យេរូសាឡឹមក៏ដោយ ក៏សន្តិភាពនោះមិនបានមានដល់យេរូសាឡឹមទេពីព្រោះពួកគេបានបះបោរប្រឆាំងនឹងព្រះ។ ការនេះគួរតែលើកទឹកចិត្តយើងមិនឲ្យគ្រាន់តែអធិស្ឋានប៉ុណ្ណោះទេ ប៉ុន្តែយើងក៏ត្រូវបង្ហាញការចុះចូលតាមសេចក្តីជំនឿចំពោះព្រះបន្ទូលរបស់ព្រះនៅក្នុងជីវិតរបស់យើងនៅពេលយើងសំលឹងឆ្ពោះទៅកាន់យេរូសាឡឹមថ្មីដែលយើងនឹងមានសិទ្ធិចូលដោយសារតែយញ្ញបូជារបស់ព្រះយេស៊ូវសំរាប់យើង។

**Bibliography**

Carson, D.A., R. T. France, J. A. Motyer & G. J. Wenham, Ed. (1994), *New Bible commentary: 21st century edition*, (4th ed.) Leicester, England; Downers Grove, IL: Inter-Varsity Press.

Henry, M. (1994), *Matthew Henry's commentary on the whole Bible: Complete and unabridged in one volume*, Peabody: Hendrickson.

Kidner, D. (1975). *Vol. 16*: *Psalms 73–150: An Introduction and Commentary*. Tyndale Old Testament Commentaries. Nottingham, England: Inter-Varsity Press.

Matthews, V. H., M. W. Chavalas & J.H. Walton (2000), *The IVP Bible background commentary: Old Testament*, Downers Grove, IL: InterVarsity Press.

Wilcock, Michael. (2001), *The Message of Psalms 73-150.* The Bible Speaks Today Commentaries. Leicester, England: Inter-Varsity Press.